VACCINE INFORMATION STATEMENT (សេចក្តីថ្លែងព័ត៌មានអំពីវ៉ាក់សាំង)

# វ៉ាក់សាំង RSV (វីរុសបង្កឱ្យមានជំងឺផ្លូវដង្ហើម)៖ *អ្វីដែលអ្នកត្រូវដឹង*

Many Vaccine Information Statements are available in Khmer and other languages. See www.immunize.org/vis

សេចក្តីថ្លែងការណ៍នៃព័ត៌មានអំពីវ៉ាក់សាំងជាច្រើនគឺអាចរកបានជាភាសាខ្មែរ និងភាសាផ្សេងទៀត។ ចូលមើល www.immunize.org/vis

## *1.* ហេតុអ្វីត្រូវចាក់ថ្នាំវ៉ាក់សាំង?

**វ៉ាក់សាំង** RSV អាចកាត់បន្ថយជំងឺផ្លូវដង្ហើម ដែលបណ្តាលមកពី **វីរុសបង្កឱ្យមានជំងឺផ្លូវដង្ហើម** (RSV)។ RSV គឺជាវីរុសផ្លូវដង្ហើមទូទៅ ដែលជាធម្មតាបណ្តាលឱ្យមានរោគសញ្ញាស្រាល និងដូចជាផ្តាសាយ។

RSV អាចបង្កឱ្យមានជំងឺនៅក្នុងចំណោមមនុស្សគ្រប់វ័យ ប៉ុន្តែអាចធ្ងន់ធ្ងរជាពិសេសចំពោះទារក និងមនុស្សចាស់ពេញវ័យ។

- RSV គឺជាមូលហេតុទូទៅបំផុតនៃការចូលសម្រាកពេទ្យសម្រាប់ទារកនៅសហរដ្ឋអាមេរិក។ ទារកអាយុរហូតដល់ 12 ខែ (ជាពិសេសទារកដែលមានអាយុ 6 ខែ និងតូចជាងនេះ) និងកុមារដែលកើតមិនគ្រប់ខែ ឬដែលមានជំងឺសួត ឬជំងឺបេះដូងរ៉ាំរ៉ៃ ឬប្រព័ន្ធភាពស៊ាំចុះខ្សោយ មានហានិភ័យខ្ពស់នៃជំងឺ RSV ធ្ងន់ធ្ងរ។
- ការឆ្លងមេរោគ RSV អាចមានគ្រោះថ្នាក់សម្រាប់មនុស្សពេញវ័យមួយចំនួន។ មនុស្សពេញវ័យដែលមានហានិភ័យខ្ពស់បំផុតសម្រាប់ជំងឺ RSV ធ្ងន់ធ្ងររួមមានមនុស្សចាស់ពេញវ័យ មនុស្សពេញវ័យដែលមានស្ថានភាពជំងឺរ៉ាំរ៉ៃដូចជាជំងឺបេះដូង ឬសួត ប្រព័ន្ធភាពស៊ាំចុះខ្សោយ ស្ថានភាពជំងឺប្រចាំកាយជាក់លាក់មួយចំនួនផ្សេងទៀត ឬអ្នកដែលរស់នៅក្នុងមណ្ឌលថែទាំ ឬកន្លែងថែទាំ។

RSV ឆ្លងតាមរយៈការប៉ះពាល់ផ្ទាល់ជាមួយវីរុស ដូចជានៅពេលដែរដំណក់តូចៗចេញពីការក្អក ឬកណ្តាស់របស់អ្នកដទៃដែលប៉ះភ្នែក ច្រមុះ ឬមាត់របស់អ្នក។ វាក៏អាចឆ្លងដោយនរណាម្នាក់ប៉ះផ្ទៃ ដូចជា ដែលមានវីរុសនៅលើវា ដូចជាដៃទ្វារកាន់បិទបើកដែលមានមេរោគនៅលើនោះ ហើយបន្ទាប់មកប៉ះមុខរបស់អ្នក។

រោគសញ្ញានៃការឆ្លងមេរោគ RSV អាចរួមមានការហៀរសំបោរ ការថយចុះនៃចំណង់បរិភោគ ការក្អក ការកណ្តាស់ គ្រុនក្តៅ ឬដកដង្ហើមក្រើតក្រត។ ចំពោះទារកដែលនៅក្មេងខ្ចី រោគសញ្ញានៃ RSV ក៏អាចរួមបញ្ចូលការឆាប់ខឹង (ភាពច្របូកច្របល់) ការថយចុះសកម្មភាព ឬការគេងមិនដកដង្ហើម (ផ្អាកក្នុងការដកដង្ហើមលើសពី 10 វិនាទី)។

មនុស្សភាគច្រើនជាសះស្បើយក្នុងរយៈពេលមួយឬពីរសប្តាហ៍ ប៉ុន្តែ RSV អាចធ្ងន់ធ្ងរ ដែលបណ្តាលឱ្យមានការដកដង្ហើមខ្លី និងកម្រិតអុកស៊ីសែនទាប។ RSV អាចបណ្តាលឱ្យរលាកទងសួត (ការរលាកនៃផ្លូវដង្ហើមតូចនៅក្នុងសួត) និងជំងឺរលាកសួត (ការឆ្លងរោគនៃសួត) ។ RSV ក៏អាចនាំឱ្យលក្ខខណ្ឌវេជ្ជសាស្ត្រផ្សេងទៀតកាន់តែអាក្រក់ទៅៗ ដូចជាជំងឺហឺត ជំងឺស្ទះសួតរ៉ាំរ៉ៃ (ជំងឺរ៉ាំរ៉ៃនៃសួតដែលធ្វើឱ្យការពិបាកដកដង្ហើម) ឬជំងឺខ្សោយបេះដូង (នៅពេលដែលបេះដូងមិនអាចបូមឈាម និងអុកស៊ីហ្សែនបានគ្រប់គ្រាន់ពីទូទាំងរាងកាយ)។

មនុស្សពេញវ័យ និងទារកដែលឈឺខ្លាំងពី RSV ប្រហែលជាត្រូវសម្រាកនៅមន្ទីរពេទ្យ។ អ្នកខ្លះអាចស្លាប់បាន។

## *2.* វ៉ាក់សាំង *RSV*

មានជម្រើសការចាក់ថ្នាំការពាររោគពីរដែលមានសម្រាប់ការការពារទារកប្រឆាំងនឹង RSV៖ វ៉ាក់សាំងមាតាសម្រាប់អ្នកមានផ្ទៃពោះ ឬអង្គបដិប្រាណការពារដែលត្រូវបានផ្តល់ឱ្យទារក។ មានតែជម្រើសមួយក្នុងចំណោមជម្រើសទាំងនេះប៉ុណ្ណោះដែលត្រូវការសម្រាប់ទារកភាគច្រើនដើម្បីការពារ។

CDC ណែនាំវ៉ាក់សាំង RSV តែមួយដូសសម្រាប់**ស្ត្រីមានផ្ទៃពោះចាប់ពីសប្តាហ៍ទី 32 ដល់សប្តាហ៍ទី 36** សម្រាប់ការបង្ការជំងឺ RSV ចំពោះទារករបស់ពួកគេក្នុងអំឡុងពេលអាយុក្រោម 6 ខែ។ វ៉ាក់សាំងនេះត្រូវបានណែនាំឲ្យចាក់ចាប់ពីខែកញ្ញាដល់ខែមករាសម្រាប់រដ្ឋភាគច្រើននៃសហរដ្ឋអាមេរិក។ ទោះជាយ៉ាងណាក៏ដោយ នៅក្នុងទីតាំងមួយចំនួន (ឧទាហរណ៍ ទឹកដី ហាវ៉ៃ អាឡាស្កា និងផ្នែកខ្លះនៃរដ្ឋផ្លរីដា) ការកំណត់ពេលវេលានៃការចាក់ថ្នាំបង្ការអាចខុសគ្នាដោយផ្អែកលើពេលវេលានៃឆ្នាំដែល RSV ចរាចរនៅក្នុងតំបន់នោះ។

CDC ណែនាំឱ្យចាក់វ៉ាក់សាំង RSV តែមួយដូសក្នុងមួយដង សម្រាប់ **មនុស្សគ្រប់រូបដែលមានអាយុចាប់ពី 75 ឆ្នាំឡើងទៅ** និងសម្រាប់ **មនុស្សពេញវ័យដែលមានអាយុពី 60 ទៅ 74 ឆ្នាំដែលមានហានិភ័យខ្ពស់នៃជំងឺ RSV ធ្ងន់ធ្ងរ**។ មនុស្សពេញវ័យដែលមានអាយុចាប់ពី 60 ដល់ 74 ឆ្នាំដែលមានហានិភ័យកើនឡើងរួមមានអ្នកដែលមានជំងឺបេះដូង ឬសួតរ៉ាំរ៉ៃ ប្រព័ន្ធភាពស៊ាំចុះខ្សោយ ឬស្ថានភាពជំងឺរ៉ាំរ៉ៃមួយចំនួនផ្សេងទៀត និងអ្នកដែលរស់នៅក្នុងមណ្ឌលថែទាំ។

វ៉ាក់សាំង RSV អាចចាក់ឲ្យក្នុងពេលដំណាលគ្នានឹងវ៉ាក់សាំងដទៃទៀត។

U.S. CENTERS FOR DISEASE CONTROL AND PREVENTION

## 3. និយាយជាមួយអ្នកផ្តល់សេវាថែទាំសុខភាពរបស់អ្នក

សូមប្រាប់អ្នកផ្តល់ការចាក់វ៉ាក់សាំងរបស់អ្នក ប្រសិនបើបុគ្គលនោះទទួលវ៉ាក់សាំង៖

- ធ្លាប់មាន**ប្រតិកម្មអាឡែហ្សីបន្ទាប់ពីវ៉ាក់សាំង** RSV **ដូសមុន** ឬមាន**អាឡែហ្សីធ្ងន់ធ្ងរដែលគំរាមកំហែងដល់អាយុជីវិត**

ក្នុងករណីខ្លះ អ្នកផ្តល់សេវាថែទាំសុខភាពរបស់អ្នក អាចសម្រេចចិត្តពន្យារពេលការចាក់វ៉ាក់សាំង RSV រហូតដល់ការណាត់ជួបនាពេលខាងមុខ។

អ្នកដែលមានជំងឺស្រាល ដូចជាជំងឺផ្តាសាយ អាចទទួលការចាក់វ៉ាក់សាំងនេះបាន។ អ្នកដែលមានជំងឺធ្ងន់ល្មម ឬធ្ងន់ធ្ងរ ជាធម្មតាគួររង់ចាំ រហូតដល់ពួកគេជាសះស្បើយសិន មុនពេលទទួលវ៉ាក់សាំង RSV។

អ្នកផ្តល់សេវាថែទាំសុខភាពរបស់អ្នកអាចផ្តល់ព័ត៌មានបន្ថែមដល់អ្នកបាន។

## 4. ហានិភ័យកើតប្រតិកម្មវ៉ាក់សាំង

- ការឈឺចាប់ ក្រហម និងហើមនៅកន្លែងចាក់ថ្នាំ អស់កម្លាំង (មានអារម្មណ៍អស់កម្លាំង) គ្រុនក្តៅ ឈឺក្បាល ចង្អោរ រាគ និងឈឺសាច់ដុំ ឬសន្លាក់អាចកើតឡើងបន្ទាប់ពីចាក់វ៉ាក់សាំង RSV។

ស្ថានភាពប្រព័ន្ធប្រសាទធ្ងន់ធ្ងរ រួមទាំងរោគសញ្ញា Guillain-Barré (GBS) ត្រូវបានគេរាយការណ៍ថាឃើញមានបន្ទាប់ពីការចាក់វ៉ាក់សាំង RSV សម្រាប់មនុស្សចាស់មួយចំនួន។ នៅពេលនេះ ការកើនឡើងហានិភ័យនៃ GBS បន្ទាប់ពីការចាក់វ៉ាក់សាំង RSV ក្នុងចំណោមមនុស្សដែលមានអាយុចាប់ពី 60 ឆ្នាំឡើងទៅ មិនអាចត្រូវបានបញ្ជាក់ ឬបដិសេធបានទេ។

ការកើតមិនគ្រប់ខែ និងសម្ពាធឈាមខ្ពស់អំឡុងពេលមានផ្ទៃពោះ រួមទាំងជំងឺក្រឡាភ្លើង ត្រូវបានគេរាយការណ៍ថាមាននៅក្នុងចំណោមអ្នកមានផ្ទៃពោះដែលបានទទួលវ៉ាក់សាំង RSV។ វាមិនច្បាស់ថាតើព្រឹត្តិការណ៍ទាំងនេះកើតឡើងដោយសារការប្រើវ៉ាក់សាំងឬទេ។

ពេលខ្លះ មនុស្សអាចសន្លប់ បន្ទាប់ពីដំណើរការវេជ្ជសាស្ត្ររួមទាំងការចាក់វ៉ាក់សាំង។ សូមប្រាប់អ្នកផ្តល់សេវាថែទាំសុខភាពរបស់អ្នក ប្រសិនបើអ្នកវិលមុខ ឬចក្ខុញ្ញាណផ្លាស់ប្តូរ ឬឮសំឡេងហឹងក្នុងត្រចៀក។

ដូចថ្នាំផ្សេងទៀតដែរ វ៉ាក់សាំងកម្រនឹងបង្កប្រតិកម្មអាលែហ្សីធ្ងន់ធ្ងរ របួសធ្ងន់ធ្ងរផ្សេងទៀត ឬធ្វើឲ្យស្លាប់បាត់បង់ជីវិតណាស់។

V-Safe គឺជាប្រព័ន្ធត្រួតពិនិត្យសុវត្ថិភាពដែលអនុញ្ញាតឱ្យអ្នកចែករំលែកជាមួយ CDC អំពីសភាពរបស់អ្នក ឬអ្នកនៅក្នុងបន្ទុករបស់អ្នកបន្ទាប់ពីទទួលវ៉ាក់សាំង RSV។ អ្នកអាចស្វែងរកព័ត៌មាន និងចុះឈ្មោះក្នុង V-Safe តាមអាសយដ្ឋាន vsafe.cdc.gov។

## 5. ចុះបើមានបញ្ហាធ្ងន់ធ្ងរ?

ប្រតិកម្មអាលែហ្សីអាចកើតឡើង បន្ទាប់ពីអ្នកទទួលការចាក់វ៉ាក់សាំងចាកចេញពីគ្លីនិក។ ប្រសិនបើអ្នកឃើញសញ្ញានៃប្រតិកម្មអាឡែហ្សីធ្ងន់ធ្ងរ (កន្ទួលក្រហម ហើមមុខ និងបំពង់ក ពិបាកដកដង្ហើម បេះដូងលោតញាប់ វិលមុខ ឬខ្សោយ) សូមទូរសព្ទទៅ **9-1-1** ហើយនាំអ្នកជំងឺទៅមន្ទីរពេទ្យដែលនៅជិតបំផុត។

សម្រាប់សញ្ញាផ្សេងទៀតដែលធ្វើឱ្យអ្នកបារម្ភ សូមទូរសព្ទទៅអ្នកផ្តល់សេវា ថែទាំសុខភាពរបស់អ្នក។

ប្រតិកម្មអាក្រក់គួរតែត្រូវបានរាយការណ៍ទៅប្រព័ន្ធរាយការណ៍ព្រឹត្តិការណ៍អាក្រក់កើតចេញវ៉ាក់សាំង Vaccine Adverse Event Reporting System (VAERS)។ អ្នកផ្តល់សេវាថែទាំសុខភាពរបស់អ្នកជាធម្មតានឹងដាក់របាយការណ៍នេះ ឬអ្នកអាចធ្វើវាដោយខ្លួនឯងបាន។ សូមចូលទៅគេហទំព័រប្រព័ន្ធរាយការណ៍ផលអាក្រក់នៃថ្នាំវ៉ាក់សាំង (VAERS) **www.vaers.hhs.gov** ឬទូរសព្ទទៅលេខ **1-800-822-7967**។ *ប្រព័ន្ធរាយការណ៍ផលអាក្រក់នៃថ្នាំ (VAERS) សម្រាប់តែការរាយការណ៍អំពីប្រតិកម្ម ហើយបុគ្គលិករបស់ប្រព័ន្ធរាយការណ៍ផលអាក្រក់នៃថ្នាំ (VAERS) មិនផ្តល់ដំបូន្មានអំពីវេជ្ជសាស្ត្រទេ។*

## 6. តើខ្ញុំអាចស្វែងយល់បន្ថែមទៀតដោយរបៀបណា?

- សូមសួរអ្នកផ្តល់សេវាថែទាំសុខភាពរបស់អ្នក។
- សូមទូរសព្ទទៅក្រសួងសុខាភិបាលរដ្ឋ ឬនៅតាមមូលដ្ឋានរបស់អ្នក។
- សូមចូលទៅគេហទំព័ររដ្ឋបាលអាហារនិងឱសថ (FDA) ដើម្បីទទួលបានកញ្ចប់វ៉ាក់សាំង និងព័ត៌មានបន្ថែមនៅឯ **www.fda.gov/vaccines-blood-biologics/vaccines**
- សូមទាក់ទងមជ្ឈមណ្ឌលសម្រាប់ការគ្រប់គ្រង និងទប់ស្កាត់ជំងឺ (Centers for Disease Control and Prevention, CDC)៖
  - សូមទូរសព្ទទៅលេខ **1-800-232-4636** (**1-800-CDC-INFO**) ឬ
  - ចូលមើលគេហទំព័ររបស់ CDC នៅឯ **www.cdc.gov/vaccines**។

Khmer translation provided by Immunize.org